**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៥២...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការលើកទឹកចិត្តពន្ធ
# សម្រាប់ប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ “A”

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

អនុក្រឹត្យនេះ មានគោលបំណងជំរុញការអភិវឌ្ឍវិស័យប្រេងកាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវការអនុគ្រោះពន្ធពិសេសចំពោះអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត ក្នុងប្លុកអេ“A” នៃកិច្ចព្រមព្រៀងប្រេងកាត ដោយអនុលោមតាមមាត្រា ១៥២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មបំពេញបន្ថែមដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧។ ការអនុគ្រោះពន្ធពិសេសនេះ សំដៅដោះស្រាយនូវអសង្គតិភាពរវាងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងប្រេងកាត រវាងរាជរដ្ឋាភិបាលកម្ពុជា និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ “A” ដែលបានធ្វើឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧។

**មាត្រា ៣.- វិសាលភាព**

ការអនុគ្រោះពន្ធពិសេសដែលបានកំណត់ក្នុងអនុក្រឹត្យនេះត្រូវបានផ្តល់ឱ្យចំពោះតែអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ “A” នៃកិច្ចព្រមព្រៀងប្រេងកាត ដែលតទៅនេះហៅថា “អ្នកជាប់ពន្ធ”។

អ្នកជាប់ពន្ធត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងពន្ធដារ និងពន្ធគយ នៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យនិងឃ្លាទាំងឡាយដែលត្រូវបានប្រើប្រាស់ក្នុងអនុក្រឹត្យនេះ មាននិយមន័យស្របគ្នាទៅនឹងនិយមន័យនៃពាក្យទាំងឡាយនៅក្នុងច្បាប់ស្តីពីសារពើពន្ធ។

## ជំពូក ២
## ការអនុគ្រោះពន្ធពិសេស

### មាត្រា ៤.- ក្រុមហ៊ុនក្នុងស្រុក

១- អនុលោមតាមវាក្យខណ្ឌ ក នៃកថាខណ្ឌ ៣ នៃមាត្រា ១៤២ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធអនិវាសនជនដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើប្រតិបត្តិការប្រេងកាតនៅក្នុងប្លុកអេ "A" ត្រូវបង្កើតជាក្រុមហ៊ុនក្នុងស្រុក ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

២- ដោយមិនគិតដល់បទប្បញ្ញត្តិដទៃស្តីពីពន្ធដារ អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវទទួលបានការអនុគ្រោះ ដូចខាងក្រោម÷

- លើកលែងពន្ធនានាទាក់ទិននឹងការផ្ទេរទ្រព្យសកម្ម ថ្លៃដើម សម្ភារបរិក្ខារ និងផលប្រយោជន៍នៃកិច្ចព្រមព្រៀង
- អនុញ្ញាតឱ្យផ្ទេរចំណាយនានា ជាអាទិ៍មាន ចំណាយបង្កើតក្រុមហ៊ុន ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលកើតមានឡើងក្រោមកិច្ចព្រមព្រៀងប្រេងកាត ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០២ រួមទាំងប្រាក់ចំណេញឬខាតទាក់ទិននឹងប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ "A" ពីក្រុមហ៊ុនអនិវាសនជនមកក្រុមហ៊ុនក្នុងស្រុកដែលបានបង្កើតតាមកថាខណ្ឌ ១ នៃមាត្រានេះ។

៣- រដ្ឋមន្ត្រី និងប្រធានស្ថាប័នដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវជួយសម្រួលដល់អ្នកជាប់ពន្ធក្នុងការបង្កើតក្រុមហ៊ុនក្នុងស្រុក ដូចដែលមានចែងក្នុងកថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃមាត្រានេះ និងផ្ទេរការអនុញ្ញាតទាំងឡាយដែលកន្លងមកបានផ្តល់ជូនអ្នកជាប់ពន្ធអនិវាសនជនទៅឱ្យក្រុមហ៊ុនក្នុងស្រុក។

### មាត្រា ៥.- ពន្ធលើប្រាក់ចំណូល

ដោយមិនគិតពីបទប្បញ្ញត្តិនៃកថាខណ្ឌ ១ នៃមាត្រា ១៤៣ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវបានអនុគ្រោះឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រា ២៥ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធសម្រាប់រយៈពេល ៥ឆ្នាំដំបូង និងតាមអត្រា ៣០ ភាគរយ សម្រាប់ឆ្នាំជាបន្តបន្ទាប់។ អត្រាពន្ធអនុគ្រោះនេះ ត្រូវចាប់អនុវត្តពីឆ្នាំដែលមានប្រាក់ចំណូលជាប់ពន្ធដំបូង ដោយមិនគិតពីការយោងការខាតបង់ឡើយ។

ប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជា។

### មាត្រា ៦.- ពន្ធកាត់ទុកលើការទូទាត់ភាគលាភ

ដោយមិនគិតពីបទប្បញ្ញត្តិនៃមាត្រា ២៦ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវបានអនុគ្រោះពន្ធកាត់ទុកលើការទូទាត់ភាគលាភ រួមទាំងការចាត់ទុកជាភាគលាភ ទៅឱ្យអ្នកជាប់ពន្ធអនិវាសនជនតាមអត្រា ០ ភាគរយ សម្រាប់រយៈពេល ៥ឆ្នាំដំបូង និងតាមអត្រា ១០ ភាគរយ សម្រាប់ឆ្នាំជាបន្តបន្ទាប់។ ការអនុគ្រោះការកាត់ទុកពន្ធលើការទូទាត់ភាគលាភនេះ ត្រូវអនុវត្តចាប់ពីឆ្នាំដែលមានប្រាក់ចំណូលជាប់ពន្ធដំបូង។

**មាត្រា ៧.- ពន្ធអប្បបរមា**

ដោយមិនគិតពីបទប្បញ្ញត្តិនៃមាត្រា ២៤ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវទទួលបានការលើកលែងពន្ធអប្បបរមា។

**មាត្រា ៨.- ពន្ធគយ**

ដោយមិនគិតពីបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា÷

១- អ្នកជាប់ពន្ធត្រូវបានលើកលែងពន្ធគយ និងអាករនានា រួមបញ្ចូលទាំងអាករលើតម្លៃបន្ថែមផង សម្រាប់ការនាំចូលមុខទំនិញមួយចំនួនដែលត្រូវប្រើប្រាស់ក្នុងប្រតិបត្តិការប្រេងកាតដូចមានក្នុងបញ្ជីដែលបានអនុញ្ញាតដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ពន្ធគយលើការនាំចេញចំពោះការលក់ផលិតផលប្រេងកាតនៃប្លុកអេ "A" ទៅក្រៅប្រទេស ត្រូវបានកំណត់តាមអត្រា ២ ភាគរយ។

**មាត្រា ៩.- អាករលើតម្លៃបន្ថែម**

គ្រប់លក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការបង្វិលសងអាករលើតម្លៃបន្ថែម ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ ត្រូវបន្តជាធរមាន។ កិច្ចព្រមព្រៀងស្តីពីការបង្វិលសងអាករលើតម្លៃបន្ថែមនេះ អាចនឹងត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុនក្នុងស្រុកដែលត្រូវបានបង្កើតឡើងដោយអ្នកជាប់ពន្ធអនិវាសនជននៃកិច្ចព្រមព្រៀងប្រេងកាត ក្នុងប្លុកអេ "A"។

ផលិតផលប្រេងកាតដែលអ្នកជាប់ពន្ធបានប្រើប្រាស់ក្នុងប្រតិបត្តិការផលិតកម្មនៃប្លុកអេ "A" ត្រូវបានលើកលែងអាករលើតម្លៃបន្ថែម។

**មាត្រា ១០.- ចំណាយថ្លៃដើម**

ដោយមិនគិតពីបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ចំនួននៃចំណាយបែងចែកឡើងវិញ ដែលត្រូវប្រើប្រាស់ជាការបង់សងវិញសម្រាប់ចំណាយថ្លៃដើមដោយស្ថាប័នឱ្យទៅអ្នកជាប់ពន្ធ និងត្រូវបានបែងចែកឱ្យអ្នកជាប់ពន្ធនានា នៃប្លុកអេ "A" ដូចមានចែងក្នុងមាត្រា ៣ ក ថ្មី នៃកិច្ចព្រមព្រៀងប្រតិបត្តិការរួមគ្នា ត្រូវចាត់ទុកជាការទូទាត់សងវិញនៃប្រាក់ឱ្យខ្ចី និងមិនមែនជាចំណូលជាប់ពន្ធឡើយ។

**មាត្រា ១១.- ការគណនាប្រាក់ពន្ធ និងការទូទាត់ប្រាក់ពន្ធ**

ដោយមិនគិតពីបទប្បញ្ញត្តិនៃផ្នែកទី ២.៤ នៃជំពូក ២ នៃប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ ការគណនាប្រាក់ពន្ធ និងការទូទាត់ប្រាក់ពន្ធ អាចធ្វើឡើងជាប្រាក់ដុល្លារសហរដ្ឋអាមេរិក។

**មាត្រា ១២.- ការប្រើប្រាស់ភាសាក្នុងលិខិតប្រកាសសារពើពន្ធ និងឯកសារពន្ធដារ**

ដោយមិនគិតពីបទប្បញ្ញត្តិនៃមាត្រា ៩០ នៃច្បាប់ស្តីពីសារពើពន្ធ គ្រប់លិខិតប្រកាសសារពើពន្ធទាំងអស់ក៏ដូចជាឯកសារ និងលិខិតទាក់ទងផ្សេងៗដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការដាក់បង្ខំឱ្យអនុវត្តតាមច្បាប់ពន្ធដារ ឬដែលជាប់ទាក់ទងនឹងបែបបទផ្សេងៗក្នុងការកំណត់ពន្ធ អាចធ្វើឡើងជាភាសាអង់គ្លេស។

## ជំពូក ៣
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-** **ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣ ៖ ១៦ ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ